# របាយការណ៍ជូនអង្គប្រជុំគណៈអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី
# ស្តីពី
# លទ្ធផលនៃការចរចាលើដំណោះស្រាយបញ្ហាព្រំដែនគោកកម្ពុជា-វៀតណាម និងករណីសុំសេចក្តីសំរេចលើសេចក្តីព្រាងសន្ធិសញ្ញាបំពេញបន្ថែម លើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ រវាងសាធារណៈរដ្ឋប្រជាមានិតកម្ពុជា និង សាធារណៈរដ្ឋសង្គមនិយមវៀតណាម

នាថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៥

គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៣ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ស្តីពីដំណោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាង គឺបន្តការចរចាដោយសន្តិវិធីក្នុងការកំណត់ខ្សែព្រំដែន ខណ្ឌព្រំសីមា បោះបង្គោលព្រំដែនដោយឈរលើមូលដ្ឋានច្បាប់ និងការអនុវត្តន៍អន្តរជាតិ ស្តីពីការទទួលស្គាល់ព្រំដែនដែលអាណានិគមបានបន្សល់ទុក នៅពេលដែលកម្ពុជាបានឯករាជនៅឆ្នាំ១៩៥៣ ។

គណៈកម្មាធិការចំរុះកិច្ចការព្រំដែន នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន បន្តអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការខិតខំរកដំណោះស្រាយជាមួយប្រទេសជិតខាងទាំង៣ ធ្វើឱ្យខ្សែព្រំដែនដែលមាននៅលើផែនទីផ្លូវការ ក្លាយទៅជាខ្សែព្រំដែនពិតប្រាកដនៅលើដីជាក់ស្តែង ក្នុងគោលដៅធានានឹងរក្សាឱ្យបាននូវផ្ទៃក្រឡាដី ១៨១ ០៣៥ គីឡូម៉ែត្រក្រឡា ។

សមិទ្ធិផលដែលរាជរដ្ឋាភិបាលទទួលបាន មានសង្ខេបដូចខាងក្រោម ៖

**ជាមួយឡាវ** ៖ គណៈកម្មការចំរុះកិច្ចការព្រំដែនកម្ពុជា-ឡាវ បានធ្វើការត្រួតពិនិត្យបាន៨៦% នៃព្រំដែនរួម និងបានបោះបង្គោលបណ្តោះអាសន្នដល់បង្គោលលេខ១៤៥ នៅតំបន់កន្ទុយនាគខេត្តរតនគិរី ។

**ជាមួយថៃ** ៖ គណៈកម្មការចំរុះកិច្ចការព្រំដែនកម្ពុជា-ថៃ បានចុះហត្ថលេខា នៅឆ្នាំ២០០០ លើអនុស្សារណៈនៃការយោគយល់គ្នា ស្តីពីការវាស់វែង និងខណ្ឌព្រំសីមាព្រំដែនគោក ដែលក្នុងនោះភាគីថៃ បានទទួលស្គាល់ជាផ្លូវការនិងជាលើកដំបូង នូវរាល់សន្ធិសញ្ញាបារាំង-សៀម ដែលបានកំណត់ ខណ្ឌសីមា រវាងឥណ្ឌូចិន និងសៀម និងឯកសារឧបសម្ព័ន្ធដូចជាពិធីសារ ផែនទី របស់គណៈកម្មការកំណត់ព្រំដែន រវាងឥណ្ឌូចិន និងសៀម ។ ភាគីទាំងពីរបានឯកភាពធ្វើបែបបទបច្ចេកទេស Term of Reference (TOR) សំរាប់ជាឧប

ករណីក្នុងការវាស់វែង និងខណ្ឌសីមាព្រំដែនគោក រវាងប្រទេសទាំងពីរ ។

**ជាមួយវៀតណាម** : ភាគីទាំងពីរបានឯកភាពគ្នាដោះស្រាយដោយសន្តិវិធី និងដោយសុទន្ធ:រួមចំពោះចំណុចព្រំដែនគោកទាំង៧ រវាងប្រទេសទាំងពីរ ។ នៅក្នុងកិច្ចចរចានៅឆ្នាំ២០០០ ភាគីទាំងពីរបានឯកភាពគ្នាលើ៦ចំណុច នៅសល់ចំណុចទី៤ នៅដាក់ដាង-ដាក់ហ៊ូត ក្នុងខេត្តមណ្ឌលគិរី នៅមិនទាន់បានដោះស្រាយ ដោយភាគីកម្ពុជាទាមទារយកខ្សែព្រំដែនដើរតាមទន្លេដាក់ហ៊ូត ដូចដែលសេចក្តីសំរេចរបស់អគ្គទេសាភិបាលឥណ្ឌូចិន ឆ្នាំ១៩១៤ បានសំរេច តែភាគីវៀតណាមទាមទារយកខ្សែដើរតាមទន្លេដាក់ដាង ដូចដែលផែនទីក្រុមភូមិសាស្ត្រឥណ្ឌូចិនបានគូស ។

ក្រោមការណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ថា ទោះបីជាយើងបានឯកភាពគ្នាតែ០៦ចំណុចក៏ដោយ ក៏យើងត្រូវតែធ្វើឯកសារផ្លូវការដើម្បីចងទុកជាភស្តុតាង ជាហេតុដែលនាំដល់ការឯកភាពគ្នានៅឆ្នាំ២០០០ លើឯកសារពីរ ដែលបានដាក់ជូនគណ:រដ្ឋមន្ត្រី នាខែធ្នូ ឆ្នាំ២០០០ អនុម័តទទួលយក គឺពង្រាងអនុស្សារណ:នៃការយល់យោគគ្នា លើ៦ចំណុច និងពង្រាងសន្ធិសញ្ញាបំពេញបន្ថែម លើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ១៩៨៥ ក្នុងករណីឯកភាពលើ៧ចំណុច ។ គួរកត់សំគាល់ថា តាំងពីឆ្នាំ១៩៩៦មក ភាគីវៀតណាមបានផ្លាស់ប្តូរប្រធានគណ:កម្មការព្រំដែនរបស់គេ៤លើករួចមកហើយ តែខាងកម្ពុជាវិញពុំមានការផ្លាស់ប្តូរទេ ដែលជាឱកាសមួយដ៏ស្មុគស្មាញ ដោយភាគីវៀតណាម បានលើកសំណើថ្មីៗនៅរាល់ការប្រជុំ ដោយគេសំអាងថា ពុំបានដឹងឬពុំមានពេលសិក្សា ដែលជាហេតុនាំឱ្យយើងខាតពេលវេលាជាច្រើន និងត្រូវការអំណត់ក្នុងការពន្យល់អ្នកថ្មី ឱ្យព្រមយកចំណុចឯកភាពលើកិច្ចការរបស់ប្រធានចាស់ជាដើម ។

នៅឱកាសប្រជុំក្រុមជំនាញ នាខែមិនា ឆ្នាំ២០០៥ ភាគីវៀតណាមបានស្នើធ្វើឯកសារថ្មី ជំនួសឯកសារដែលបានឯកភាពគ្នារួចមកហើយនោះ ដោយភាគីវៀតណាមទាមទារឱ្យភាគីកម្ពុជាទទួលស្គាល់ថា តំបន់ប៊ូប្រាងនោះ ជាតំបន់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភាគីវៀតណាម ក្នុងន័យថា វៀតណាម សុំឱ្យកម្ពុជាទទួលយកខ្សែព្រំដែនដើរតាមទន្លេដាក់ដាង ពុំមែនដាក់ហ៊ូតដូចដែលកម្ពុជាទាមទារនោះទេ ។

ការទាមទាររបស់ភាគីវៀតណាមនេះ ធ្វើឱ្យការចរចាទទួលបរាជ័យដោយពុំអាចចុះហត្ថលេខាលើកំណត់ហេតុនៃសម័យប្រជុំនាពេលនោះបាន ។ ក្រោមមកទៀតមានកិច្ចប្រជុំវិសាមញ្ញរវាងប្រធានគណ:កម្មការទទួលបន្ទុក:កិច្ចការព្រំដែន នៃប្រទេសទាំងពីរ នាថ្ងៃទី២៦-២៨ ខែមិនា ឆ្នាំ២០០៥ នៅទីក្រុងភ្នំពេញ ដើម្បីដោះស្រាយការរាំងស្ទះកន្លងមកនោះ ។ នៅក្នុងកិច្ចប្រជុំលើកនេះ ភាគីវៀតណាមបានផ្លាស់ប្តូរគោលជំហរទាំង

ស្រុង ដោយព្រមទទួលយកឯកសារដើមមកពិនិត្យឡើងវិញ និងឈប់ទាមទារឱ្យភាគីកម្ពុជាទទួលស្គាល់តំបន់ប៊ូប្រាងថា ជាតំបន់ស្ថិតនៅក្រោមការគ្រប់របស់វៀតណាម ដូចមុនទៀតហើយ ។

ការផ្លាស់ប្តូរគោលជំហរវៀតណាមនាពេលនោះ តាមសំដីរបស់លោក វូ យ៉ុង ប្រធាគណៈកម្មការព្រំដែនវៀតណាម ជាសេចក្តីសំរេចរបស់ថ្នាក់ដឹកនាំកំពូលវៀតណាម ដែលធ្វើឡើងជូនចំពោះសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ដូចជាការដែលសម្តេច ចង់ចុះហត្ថលេខាលើការឯកភាពគ្នាលើ៦ចំណុចជាដើម ភាគវៀតណាម ត្រូវតែបំពេញតាមបំណងប្រាថ្នារបស់សម្តេច ។

នៅក្រោមបរិយាកាសអំណោយផលនេះហើយ ដែលអនុញ្ញាតឱ្យភាគីទាំងពីរបានធ្វើការពិនិត្យរួមគ្នាយ៉ាងល់អិតលើពង្រាងសន្ធិសញ្ញាបំពេញបន្ថែមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ១៩៨៥ ដែលស្តែងឱ្យឃើញពីលទ្ធផលដែលទទួលបានពីកិច្ចប្រជុំនានារបស់គណៈកម្មការចំរុះកិច្ចការព្រំដែន នៃប្រទេសទាំងពីរ ចាប់តាំងពីឆ្នាំ១៩៩៩ រហូតមកដល់បច្ចុប្បន្ន ដើម្បីដាក់ជូនរដ្ឋាភិបាលរៀង៦ខ្លួនពិនិត្យ និងសំរេច ។

អត្ថបទពង្រាងសន្ធិសញ្ញាបំពេញបន្ថែម ដាក់ជូនគណៈអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី ពិនិត្យ និងអនុម័តយកនាពេលនេះ ជាអត្ថបទដែលគណៈរដ្ឋមន្ត្រីកម្ពុជា បានអនុម័តទទួលយកនាសម័យប្រជុំពេញអង្គនាថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០០ រួចម្តងទៅហើយ ដោយមានកែសំរួលចំណុចខ្លះ៦តែប៉ុណ្ណោះ ។

## I-ចំណុចឯកភាព

ក-ភាគីទាំងពីរឯកភាពអនុម័តយកគោលការណ៍ និងការដោះស្រាយមួយចំនួនដោយឈរលើមូលដ្ឋាននៃសន្ធិសញ្ញា ឆ្នាំ១៩៨៥ ដើម្បីកែសំរួលទិសដើរនៃខ្សែព្រំដែនគោក នៅតំបន់មួយចំនួនដូចខាងក្រោម :

១/បានឯកភាពគ្នាអនុវត្តយកគោលការណ៍ និងការអនុវត្តន៍អន្តរជាតិស្តីពីបញ្ហាព្រំដែនដើរតាមខ្សែទឹក ដើម្បីកំណត់ខ្សែព្រំដែនដើរតាមខ្សែទឹក នៅតាមបណ្តោយព្រំដែនគោកទាំងអស់ នៃប្រទេសទាំងពីរគឺ :

**-ចំពោះកំណាត់ព្រំដែនទឹកដែលមិនអាចធ្វើនាវាចរណ៍បាន ខ្សែព្រំដែនត្រូវដើរតាមបន្ទាត់ទ្រូងនៃខ្សែទឹកនោះ** ligne médiane ។

-ចំពោះកំណាត់ខ្សែព្រំដែនទឹក ដែលអាចធ្វើនាវាចរណ៍បាន ខ្សែព្រំដែននោះត្រូវដើរតាមបន្ទាត់ទ្រូងនៃជ្រលងទឹកជ្រៅ ligne de thalweg ។ ចំណុចនេះមានសារៈសំខាន់ណាស់ ព្រោះក្នុងការអនុវត្តន៍ជាក់ស្តែងទៅថ្ងៃក្រោយ ប្រជាពលរដ្ឋខ្មែរក៏ដូចជាពលរដ្ឋវៀតណាម ដែលរស់នៅតាមបណ្តោយខ្សែព្រំដែនទឹកទាំងនោះ មានសិទ្ធិប្រើប្រាស់ទឹកនោះ ដោយមិនចាំបាច់សុំការអនុញ្ញាតិពីភាគីម្ខាងទៀត ។

២/ក្នុងដំណាក់កាលដោះស្រាយបញ្ហាព្រំដែនគោករវាងប្រទេសទាំងពីរ ដើម្បីកំណត់ទិសដើរនៃខ្សែព្រំដែននៅតំបន់ទាំងប្រាំពីរ(៧)កន្លែង ភាគីទាំងពីរបានឯកភាពគ្នាផ្អែកលើគោលការណ៍ដើម្បីពិនិត្យ និងអនុវត្តដូចតទៅ:

-បណ្ដារគោលការណ៍មូលដ្ឋានច្បាប់ ដែលរដ្ឋបាលអាណានិគមបានប្រើប្រាស់ ក្នុងការកសាងខ្សែព្រំដែនគោកកម្ពុជា-វៀតណាម ។

-ការគ្រប់គ្រងពិតប្រាកដ និងការកាន់កាប់ជាក់ស្ដែងរបស់ប្រជាជនជាច្រើនជំនាន់ ។

-ស្ថានភាពភូមិសាស្ត្រ ឋានលេខាស្របទៅនិងបណ្ដាគោលការណ៍ច្បាប់ និងការអនុវត្តន៍អន្តរជាតិសំរាប់អនុវត្តក្នុងការកំណត់ទិសដើរនៃខ្សែព្រំដែន ដូចជាខ្សែបែងចែកទឹក ខ្សែជួរកំពូលភ្នំ ខ្សែរយៈកំពស់ ។

ខ-ដើម្បីទទួលយកលទ្ធផលនៃការឯកភាពគ្នាលើ០៦ចំណុចនោះ ប្រការ១នៃសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ បានត្រូវកែសំរួលនៅកំណាត់ព្រំដែន០៦កន្លែង ជាក់ស្ដែងដូចខាងក្រោម :

១-ចំណុចទី១ និងទី២ ខេត្តរតនគិរី ត្រង់ខ្សែព្រំដែនដែលអាណានិគមបារាំង មិនបានគូសលើតំបន់ស និងផ្ទាំងផែនទីពីរផ្គុំមិនស៊ីគ្នា ។

២-ចំណុចទី៣ នៅខេត្តមណ្ឌលគិរី និងចំណុចទី៥ នៅតំបន់ចន្លោះទន្លេមេគង្គ និងទន្លេបាសាក់ក្នុងខេត្តកណ្ដាល ដោយយកខ្សែព្រំដែននៅតំបន់នោះ តាមការកាន់កាប់ជាក់ស្ដែង ស្របទៅនិងផែនទីខ្នាត ១:១០០ ០០០ របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិន និងសេចក្ដីសំរេចរបស់អគ្គទេសាភិបាលឥណ្ឌូចិន ។

៣-ចំណុចទី០៦ និងទី០៧ ក្នុងខេត្តកណ្ដាល ភាគីទាំងពីរបានឯកភាពកែសំរួលខ្សែព្រំដែន ដោយយោងតាមសេចក្ដីសំរេចរបស់អគ្គទេសាភិបាលឥណ្ឌូចិន ឆ្នាំ១៩៤២ ។

គ-ដើម្បីបង្ករលក្ខណៈងាយស្រួលដល់ការងារបច្ចេកទេស ក្នុងការងារខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោក ភាគីទាំងពីរឯកភាពគ្នា :

១-ក្រុមជំនាញបច្ចេកទេសនៃភាគីនិមួយៗពិនិត្យ និងធ្វើការផ្ទៀងផ្ទាត់ជាឯកតោភាគី ការចម្លងឡើងវិញនូវខ្សែព្រំដែន ពីផែនទី Bonne ខ្នាត ១:១០០ ០០០ SGI មកលើផែនទី UTM ខ្នាត១:៥០ ០០០ អមសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ១៩៨៥ ។ ក្រុមជំនាញបច្ចេកទេសនៃភាគីទាំងពីរ នឹងជួបប្រជុំគ្នាមុនដំណាច់ឆ្នាំ២០០៥ ដើម្បីធ្វើការពិនិត្យប្រៀបធៀបលទ្ធផលការងាររបស់ខ្លួន និងលើកឡើងនូវដំណោះស្រាយបច្ចេកទេស ជូនទៅគណៈកម្មការចំរុះដើម្បីពិនិត្យ សំរេច ។

២-ភាគីវៀតណាម នឹងជួយភាគីកម្ពុជាបោះពុម្ពឡើងវិញនូវផែនទី UTM ខ្នាត ១:៥០ ០០០ ដែលមានឋានលេខាដូចគ្នានិងផែនទី UTM អមសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ ។ កិច្ចការនេះ តាមគំរោងត្រូវធ្វើឱ្យបានចប់សព្វគ្រប់នៅខែឧសភា ឆ្នាំ២០០៥ ។

៣-រៀបចំកិច្ចប្រជុំថ្នាក់គណៈកម្មការចំរុះកិច្ចការព្រំដែន និងថ្នាក់ជំនាញដើម្បីអនុវត្តកិច្ចការបោះបង្គោលព្រំដែនលើដីជាក់ស្តែង (ចាប់ពីឆមាសទី១ ឆ្នាំ២០០៦ រហូតដល់ឆមាសទី២ ឆ្នាំ២០០៨ ) ។

៤-ភាគីទាំងពីរនឹងខិតខំធ្វើយ៉ាងណា ដើម្បីឱ្យកិច្ចការខ័ណ្ឌព្រំសីមា និងបោះបង្គោលព្រំដែននៅលើដីជាក់ស្តែងឱ្យបានមុនដំណាច់ខែធ្នូ ឆ្នាំ២០០៨ នឹងរួមគ្នាផលិតផែនទី ឋានលេខា នៃតំបន់ព្រំដែនរវាងប្រទេសទាំងពីរ ដើម្បីធ្វើការកត់ត្រាលទ្ធផលក្នុងការបោះបង្គោល និងខ័ណ្ឌសីមាលើភូមិសាស្ត្រជាក់ស្តែង ដើម្បីផលិតផែនទីព្រំដែនផ្លូវការ រវាងប្រទេសទាំងពីរ ។

ឃ-ចំណុចសំខាន់មួយទៀតស្តីពីការផ្តល់ភារកិច្ចឱ្យគណៈកម្មការចំរុះកិច្ចការព្រំដែន នៃប្រទេសទាំងពីរ ធ្វើពិធីសារស្តីពីការបោះបង្គោល ខ័ណ្ឌសីមាព្រំដែនគោករវាងប្រទេសទាំងពីរ រួមមានបណ្តាឯកសារលំអិតស្តីពីព្រំដែន បណ្តាបង្គោលព្រំដែន និងផែនទីព្រំដែនរវាងប្រទេសទាំងពីរ ដែលសំដែងនៃទិសដើរនៃខ្សែព្រំដែន ទីតាំងបង្គោលព្រំដែន តាមបណ្តោយព្រំដែនទាំងមូល ។

ពិធីសារស្តីពីការបោះបង្គោល ខ័ណ្ឌសីមាព្រំដែនគោក គឺជាផ្នែកមួយនៃសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ១៩៨៥ និងអនុស្សារណៈនៃការយោគយល់គ្នាបំពេញបន្ថែមនេះ ។ ផែនទីព្រំដែនរវាងប្រទេសទាំងពីរ នឹងប្តូរជំនួសផែនទីបោនខ្នាត ១:១០០ ០០០ ចំនួន២៦ផ្ទាំង និងផែនទី UTM ខ្នាត១:៥០ ០០០ ចំនួន៤០ផ្ទាំង ដែលអមសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ១៩៨៥ និងប្លង់ទាំង៥ អមសន្ធិសញ្ញាបំពេញបន្ថែម ។

II-ចំណុចស្នើកែដោយភាគីវៀតណាម មានដូចតទៅ :

១-សុំកែគ្រប់ពាក្យ " សន្ធិសញ្ញា ទៅជា អនុស្សារណៈនៃការយោគយល់គ្នា " វិញ ។

២-សុំកែ " ប្រធានរដ្ឋ " ទៅជា ប្រធាន " ។

៣-ប្រការ ២ កថាខណ្ឌ ១ សុំកែ " ព្រាំពីរ " មក " ព្រាំមួយ " វិញ ។

៤-ប្រការ ២ ចំណុចទី៦សុំកែបន្ថែម " កំណាត់ព្រំដែននៅតំបន់ជាប់និងឃុំដាក់ដាំ ស្រុកអូរាំង ខេត្តមណ្ឌលគិរី-កម្ពុជា និងឃុំភាងជិក ស្រុកដាក់ម៉ើប ខេត្តដាឡាក់ (ដាក់នង) វៀតណាម ភាគីគូរសន្យាទាំងពីរបានឯកភាពគ្នា បន្តការចរចារហូតដល់រកដំណោះស្រាយបានសមស្របទៅនិងមាត្រា១ នៃសន្ធិសញ្ញានេះ និងសុំលប់ចោលកថាខណ្ឌទី២ នៃចំណុចទី ០៦នេះ ។

៥-ប្រការ 3 ចំណុចទី២ សុំលប់ចោលឃ្លា " ភាគីកម្ពុជា នឹងបញ្ជូន ... ខាងលើ " ដោយជំនួសឃ្លាថា " កិច្ចការនេះ នឹងត្រូវបញ្ចប់នៅខែឧសភា ឆ្នាំ២០០៥ " ។ និងសុំបន្ថែម : ចំណុចទី៣ រៀបចំកិច្ចប្រជុំថ្នាក់គណៈកម្មការចំរុះកិច្ចការព្រំដែន និងថ្នាក់ជំនាញដើម្បីអនុវត្តកិច្ចការបោះបង្គោលព្រំដែន លើដីជាក់ស្តែង

(ចាប់ពីឆមាសទី១ ឆ្នាំ២០០៦ រហូតដល់ឆមាសទី២ ឆ្នាំ២០០៨) ។ ចំណុចទី៤ សុំកែចំណុចទី៣ចាស់: ភាគីទាំងពីរនឹងខិតខំធ្វើយ៉ាង ណាដើម្បីឱ្យកិច្ចការខ័ណ្ឌព្រំសីមា និងបោះបង្គោលព្រំដែន នៅលើដីជាក់ស្តែង ឱ្យបានមុនដំណាច់ខែធ្នូ ឆ្នាំ ២០០៨ និងរួមគ្នាផលិតផែនទី ឋានលេខា នៃតំបន់ព្រំដែនរវាងប្រទេសទាំងពីរ ដើម្បីធ្វើការកត់ត្រាលទ្ធផល នៃការបោះបង្គោល និងខ័ណ្ឌសីមាលើភូមិសាស្ត្រជាក់ស្តែង ដើម្បីផលិតផែនទីព្រំដែនផ្លូវការ រវាងប្រទេសទាំងពីរ ។

ចំណុចមួយទៀតដែលភាគីទាំងពីរពុំទាន់បានឯកភាពគ្នានៅឡើយ ស្តីពីចំណងជើងឯកសារ ដែលត្រូវចុះហត្ថលេខានាពេលខាងមុខ ។ ភាគីកម្ពុជាយល់ឃើញថា តាមខ្លឹមសារឯកសារដែលស្នើកែឡើងដោយភាគីវៀតណាម ភាគីទាំងពីរគួរធ្វើជាសន្ធិសញ្ញាបំពេញបន្ថែម ដើម្បីកែប្រែសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ ១៩៨៥ ទោះជាភាគីទាំងពីរបានឯកភាពគ្នាតែលើ០៦ចំណុចក៏ដោយ ។

ចំពោះភាគីវៀតណាម ទោះឯកសារនោះមានឈ្មោះហៅថា អនុស្សារណៈនៃការយោគយល់គ្នា ឬអនុសញ្ញា ឬសន្ធិសញ្ញាអ្វីក៏ដោយ តាមច្បាប់វៀតណាមត្រូវតែសភាអនុម័តយល់ព្រម និងផ្តល់សច្ចាប័នពីប្រមុខរដ្ឋ ។ ចំពោះកម្ពុជាយើងវិញ យោងតាមមាត្រា ៩០ និងមាត្រា២៦ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ " សភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ " ហើយ " ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័ន លើសន្ធិសញ្ញានិងអនុសញ្ញាទាំងនោះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា " ។

ចំណុចសំខាន់ៗនៃឯកសារដាក់ជូនគណៈអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី ដើម្បីសុំសេចក្តីសំរេចនាពេលនេះគឺ សេចក្តីព្រាងសន្ធិសញ្ញាបំពេញបន្ថែម លើសន្ធិសញ្ញាកំណត់កំណត់ព្រំដែនរដ្ឋ ឆ្នាំ១៩៨៥ ដែលរាជរដ្ឋាភិបាលត្រូវចុះហត្ថលេខាជាមួយភាគីវៀតណាមនាពេលខាងមុខនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៥

**ប្រធានគណៈកម្មាធិការចំរុះកិច្ចការព្រំដែន**

**វ៉ា គឹមហុង**